# *យើងខ្ញុំត្រូវការជំនួយរបស់លោកអ្នក!*

គ្រួសារដែលកំពុងទទួលសេវាអន្តរាគមន៍បឋមវ័យ (Early Intervention Services) ត្រូវបានស្នើសុំ ឲ្យបំពេញការស្ទង់មតិ ដើម្បីបង្ហាញថាតើសេវាកម្មទាំងនេះបានជួយកូន និងគ្រួសាររបស់គាត់ឬទេ។ **រដ្ឋវ៉ាស៊ីនតោនត្រូវបានតម្រូវ ឲ្យធ្វើរបាយការណ៍ជូនរដ្ឋាភិបាលសហព័ន្ធ**រៀងរាល់ឆ្នាំ ដើម្បីបញ្ជាក់ថា សេវាអន្តរាគមន៍បឋមវ័យបានផ្តល់លទ្ធផលល្អជាវិជ្ជមានដល់ក្មេង និងគ្រួសាររបស់ក្មេង ដែលទទួលបានសេវាកម្មទាំងនេះ។ យើងខ្ញុំត្រូវការជំនួយរបស់លោកអ្នក ដើម្បីប្រមូលពត៌មានទាំងនេះ។

បុគ្គលិកសម្របសម្រួលធនធានគ្រួសារ (Family Resources Coordinator, FRC) របស់លោកអ្នកនឹងស្នើសុំលោកអ្នក ឲ្យបំពេញការស្ទង់មតិ ក្នុងខណៈដែលកូនរបស់លោកអ្នកកំពុងទទួលសេវាកម្មនេះ និងនៅពេលដែលកូនរបស់លោកអ្នកចាកចេញពីកម្មវិធីអន្តរាគមន៍បឋមវ័យ។ លោកអ្នកអាចបំពេញការស្ទង់មតិនេះតាមអ៊ីនធឺណិតក៏បាន ឬបំពេញវាលើទម្រង់ក្រដាស ដែលទទួលបានពីបុគ្គលិក FRC របស់លោកអ្នកក៏បាន។

***សូមមេត្តាជួយយើងខ្ញុំ ដើម្បីប្រមូលពត៌មានទាំងនេះ ទៅបង្ហាញរដ្ឋាភិបាលសហព័ន្ធថា កម្មវិធីអន្តរាគមន៍បឋមវ័យពិតជាមានប្រសិទ្ធភាព ហើយគួរតែទទួលបានប្រាក់ឧបត្ថម្ភបន្តទៅទៀត។***

លោកអ្នកអាចបំពេញការស្ទង់មតិគ្រួសារ (Family Survey) តាមអ៊ីនធឺណិតនៅ ៖ **www.del.wa.gov/esit**

សូមទាក់ទងបុគ្គលិក FRC បើសិនជាលោកអ្នកមានសំណួរបន្ថែម។

*សូមអរគុណ!*

Washington State Department of

**Early Learning**

Early Support
for Infants
and Toddlers

DEL 11-007 CA (6/11)